**មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា**
**Cambodian Center for Human Rights**

# សេចក្តីថ្លែងការណ៍

ភ្នំពេញថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១១

## <u>ចូលរួមគាំទ្រសិទ្ធិមនុស្សរបស់អ្នកស្រលាញ់ភេទដូចគ្នានិងអ្នកប្តូរភេទ</u>

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ស្វាគមន៍ទិវាអន្តរជាតិ ប្រឆាំង នឹង ការរើសអើង អ្នកស្រលាញ់ភេទដូចគ្នា និងអ្នកប្តូរភេទ និង ស្នើសូមឱ្យប្រជាពលរដ្ឋទាំងអស់មានការគោរព សិទ្ធិអ្នកដែលស្រលាញ់ភេទដូចគ្នា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ស្វាគមន៍ទិវាអន្តរជាតិ ប្រឆាំង នឹង ការរើសអើង អ្នកស្រលាញ់ភេទដូចគ្នា និង អ្នកប្តូរភេទ (“IDAHO”) ដែលជាទិវាមួយត្រូវបានរៀបចំធ្វើឡើងនៅជុំវិញ ពិភពលោកដើម្បីប្រារព្ធភាពចម្រុះផ្សេងៗគ្នា ហើយ និងផ្សព្វផ្សាយការគាំទ្រឱ្យ ប្រជាពលរដ្ឋទាំងអស់ មាន ការគោរពសិទ្ធិអ្នកដែលស្រលាញ់ភេទដូចគ្នា (“LGBT”) ដែលរស់នៅគ្រប់ទីកន្លែង។ សារសំខាន់ដែលបង្ហាញចេញពី IDAHO គឺអ្នកស្រលាញ់ភេទដូចគ្នា និងអ្នកប្តូរភេទដែលវាមិនមែនគ្រាន់តែអ្នកដែលស្រលាញ់ភេទផ្ទុយគ្នានោះទេ និង លក្ខណៈចម្រុះផ្សេងៗគ្នាដែលមានមតិមួយចំនួនយល់ថា អ្នកស្រលាញ់ភេទដូចគ្នាបាន ធ្វើឱ្យ សង្គមមានភាពអាប់ឱនកិត្តិសព្ទ័ និង ត្រូវបានគេស្អប់ខ្ពើម។

ដូចដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានធ្វើការកត់ត្រាក្នុងរបាយការណ៏ឆ្នាំ២០១០“*ចេញជាជំហរនៅព្រះរាជាណាចក្រកម្ពុជា: ពលរដ្ឋខ្មែរដែលស្រលាញ់ភេទដូចគ្នា”* បានបង្ហាញឱ្យឃើញថាក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកស្រលាញ់ភេទដូចគ្នា ហើយ និងអ្នកប្តូរភេទ បច្ចុប្បន្នរងការឈឺចាប់ដោយសារការរើសអើង ការរំលោភបំពាន ហើយ ជាងនេះទៅទៀត គឺរងនូវអំពើហិង្សាផ្សេងៗ។ អ្នកដែលស្រលាញ់ភេទដូចគ្នា និង អ្នកប្តូរភេទទាំងនោះ ត្រូវបានបណ្តេញចេញ និង មិនទទួលស្គាល់ពីក្រុមគ្រួសាររបស់ពួកគេ ត្រូវបានសង្គមបដិសេធឱកាសការងារ ទទួលរងនូវការរើសអើងនៅកន្លែងធ្វើការ ក្លាយជាជនរងគ្រោះធ្វើបាបពីសំណាក់ប៉ូលិស ហើយត្រូវបានបង្ខាំងពីការជួបជុំបញ្ចេញមតិ ដោយសេរីនៅទីសាធារណៈ និង ការបញ្ចេញមតិ រវាងគ្នាទៅវិញទៅមក។

ពលរដ្ឋស្រលាញ់ភេទដូចគ្នា គឺជាមនុស្សដូចពលរដ្ឋផ្សេងៗទៀតដែរ ដូចនេះពួកគេត្រូវតែទទួលបាននូវសិទ្ធិស្មើគ្នា។ ដូចដែលបាន

ចែងក្នុង សេចក្តីប្រកាសសិទ្ធិមនុស្សជាសកល ច្បាប់សិទ្ធិមនុស្សអន្តរជាតិជាច្រើនទៀតដែលព្រះរាជាណាចក្រកម្ពុជា បានចុះសច្ចាបន័ និង ច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានបង្ហាញថាសិទ្ធិមនុស្សគឺ ជាសិទ្ធិសំរាប់យើងទាំងអស់គ្នា- ដោយមិនមានភាពខុសប្លែកពីគ្នាឡើយ។ មនុស្សទាំងអស់ត្រូវទទួលស្គាល់នូវការពិតនេះដោយ មានការគោរពសិទ្ធិរបស់អ្នកដែលស្រលាញ់ភេទដូចគ្នា និង អ្នកប្តូរភេទដូចជាសិទ្ធិរបស់មនុស្ស ដ៏ទៃទៀតដែរ។

លោក អ៊ូ វីរៈ ប្រធាន មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ដែលជាអង្គការមិនមែនរដ្ឋាភិបាល មិនមាននិន្នាការនយោបាយ ឯករាជ្យ ឈានមុខមួយដែលធ្វើការលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា បានមានប្រសាសថា *"ប្រទេសកម្ពុជា បានមានការយល់ខុស ជាយូរទៅលើអ្នកដែលស្រលាញ់ភេទដូចគ្នា និង អ្នកប្តូរភេទថាមាន លក្ខណៈខុសប្រក្រតីពី 'មនុស្សធម្មតា' ដូចនេះអ្នកដែលស្រលាញ់ភេទដូចគ្នា និង អ្នកប្តូរភេទមិនមានសិទ្ធិដូច ជាមនុស្សដ៏ទៃទៀតទេ។ ពេលនេះគឺជាពេលដែលមនុស្សទាំងអស់ គួរកត់សំគាល់និងជ្រាបថា អ្នកដែលស្រលាញ់ភេទដូចគ្នា និងអ្នកប្តូរភេទមានសិទ្ធិ ដូចជាមនុស្សទាំងអស់គ្នាដែរ ដែលសមស្របទៅនឹង រដ្ឋាភិបាលកម្ពុជាក្នុងការគាំទ្រ ទៅនឹងវប្បធម៌ដែលមានការទទួលយក និង គោរពគ្នាទៅវិញទៅមក នៅក្នុងសង្គម។ សង្គម ដែលមាន ភាពជឿនលឿន ត្រូវបានពង្រឹងដោយភាពចម្រុះគ្នា"*។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា គាំទ្រឱ្យអ្នកទាំងអស់គ្នា ពាក់(ប្រើប្រាស់)ក្រមាឥន្ទ្រ ដើម្បីអបអរសាទរថ្ងៃ IDAHO បង្ហាញពីការគោរពសិទ្ធិរបស់អ្នកដែលស្រលាញ់ភេទដូចគ្នា និងអ្នកប្តូរភេទនៅក្នុង ប្រទេសកម្ពុជា។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានផ្តួចផ្តើមធ្វើក្រមាឥន្ទ្រដែលជាពណ៌នៃមោទនភាព ទិវាអន្តរជាតិអ្នកដែលស្រលាញ់ភេទដូចគ្នានិងអ្នកប្តូរភេទ-មានដាក់បង្ហាញ និងអាចជាវបាននៅ មជ្ឈមណ្ឌល សិទ្ធិមនុស្សកម្ពុជា ក្នុងទីក្រុងភ្នំពេញ។

សំរាប់ពត៌មានលំអិត សូមទំនាក់ទំនង លោក អ៊ូ វីរៈ ដែលមានទូរសព្ទ័លេខ +855(0) 12 40 40 51 រឺតាមអ៊ីមែល ouvirak@cchrcambodia.org.